# ព្រឹត្តិបត្រព័ត៌មាន

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)

គ.ជ.ប NEC BULLETIN

លេខ ៧ ចេញផ្សាយថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣

Issue 7 : 17 / 7 / 2023


# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

(ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣)

## គ.ជ.ប រៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីការចាប់ផ្តើមដំណើរការនៃការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣



ឯកឧត្តម ខឹម សុវណ្ណារុំ សមាជិក គ.ជ.ប
និងជាប្រធានក្រុមប្រតិកម្មព័ត៌មាន

នាព្រឹកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ១០:០០ នៅសាលសន្និសីទរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានរៀបចំកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធនឹងការបោះឆ្នោត ក្រោមអធិបតីភាព ឯកឧត្តម **ខឹម សុវណ្ណារុំ** សមាជិក គ.ជ.ប ប្រធាន



តទៅទំព័រទី២

**មាតិកា៖** **ទំព័រ**


- គ.ជ.ប រៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីការចាប់ផ្តើមដំណើរការនៃការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ .........១
- គ.ជ.ប ដាក់បង្ហាញ និងធ្វើតេស្តទឹកខ្មៅលុបមិនជ្រះសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ .........៥
- ស្ថានភាពទូទៅនៃការឃោសនាបោះឆ្នោត រយៈពេល ១០ ថ្ងៃ ........................................................................៨
- អ្នកណែនាំឱ្យប្រជាពលរដ្ឋគូសសន្លឹកឆ្នោតចោលនៅពេលទៅបោះឆ្នោត នឹងត្រូវផ្តន្ទាទោសតាមច្បាប់ ......................១០
- បម្រាមចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ...១១
- បម្រាមចំពោះអ្នកសង្កេតការណ៍ ក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ............១២
- សេចក្តីអំពាវនាវ ស្តីពីការបង្កលក្ខណៈងាយស្រួលដល់និយោជិក កម្មករ-កម្មការីបានទៅបោះឆ្នោត ...........................១៤
- លទ្ធផលផ្លូវការនៃការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ .........១៥

តមកពីទំព័រទី១ **គ.ជ.ប រៀបចំកិច្ចប្រជុំ...**

ក្រុមប្រតិកម្មព័ត៌មាន គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំ ដើម្បីផ្សព្វផ្សាយអំពីការចាប់ផ្តើមដំណើរការនៃការឃោសនាបោះឆ្នោត និងការរក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងពេលឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

ឯកឧត្តម **ឌឹម សុវណ្ណារុំ** បានថ្លែងថា ការឃោសនាបោះឆ្នោតត្រូវប្រព្រឹត្តទៅចាប់ពីថ្ងៃទី១ រហូតដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ សរុបមានរយៈពេល ២១ ថ្ងៃ។ គណបក្សនយោបាយដែលត្រូវបានទទួលស្គាល់ជាផ្លូវការដោយ គ.ជ.ប ចំនួន ១៨ មានសិទ្ធិធ្វើការឃោសនារកសំឡេងឆ្នោត ដោយគោរពទៅតាមច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត សេចក្តីណែនាំស្តីពី



**តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ**

ការឃោសនាបោះឆ្នោត ក្នុងស្មារតីទទួលខុសត្រូវ និងត្រូវមានការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក។ ឯកឧត្តមបានជម្រាបជូនអំពីសកម្មភាពដែលចាត់ទុកជាការឃោសនាបោះឆ្នោត មានដូចជា ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ នៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការជួបជុំ ឬការឃោសនានៅតាមផ្ទះ សកម្មភាពចែកខិត្តប័ណ្ណរបស់គណបក្សនយោបាយ។ល។

ចំពោះការហែក្បួនឃោសនាបោះឆ្នោត ឯកឧត្តម **ឌឹម សុវណ្ណារុំ** បានមានប្រសាសន៍ថា ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានធ្វើយ៉ាងច្រើន ៤ ដង ស្ថិតក្នុងព្រំប្រទល់រាជធានី ខេត្ត



**គណៈអធិបតីក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ**

ដែលសាមីគណបក្សនយោបាយមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។ ទម្រង់ និងទំហំនៃការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានកំណត់ដូចខាងក្រោម៖

- ការរៀបចំជាក្បួន មានបិទបដា ឬ/និងពាក្យស្លោក ឬ/និងសារនយោបាយផ្សេងៗ ភ្ជាប់នឹងរថយន្ត ឬ/និងទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្ត ឬជលយានគ្រប់ប្រភេទ និងមានការចាក់ផ្សាយដោយឧបករណ៍បំពងសំឡេង
- មានអ្នកចូលរួមចាប់ពី ២០ នាក់ ឡើងទៅ ដោយក្រុមថ្មើរជើង ឬ/និងប្រើប្រាស់យានជំនិះតាមប្រភេទណាមួយ ឬទាំងអស់ក្នុងការឃោសនាបោះឆ្នោត មាន៖
  - រថយន្តចាប់ពី ២ គ្រឿង ឡើងទៅ អមដោយទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្ត ចាប់ពី ១០ គ្រឿង ឡើងទៅ
  - ទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្តចាប់ពី



**តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ**

២០ គ្រឿង ឡើងទៅ និង

• ជលយានគ្រប់ប្រភេទចាប់ពី ៥ គ្រឿង ឡើងទៅ។

ឯកឧត្តម **ឌឹម សុវណ្ណារុំ** បានមានប្រសាសន៍បន្តទៀតថា គណបក្សនយោបាយដែលមានបំណងហែក្បួនឃោសនាបោះ-ឆ្នោត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គជ.ខប) យ៉ាងតិចឱ្យបាន ៣ ថ្ងៃ មុនថ្ងៃហែក្បួនឃោសនាបោះឆ្នោត ។ ការជូនដំណឹងនេះ ត្រូវបញ្ជាក់ព័ត៌មានឱ្យបានច្បាស់លាស់អំពីកាលបរិច្ឆេទពេលវេលា នៃការហែក្បួន ទីតាំងប្រមូលផ្តុំ តម្រាយផ្លូវដែលត្រូវហែក្បួន ទីតាំងរំសាយ ចំនួនអ្នកចូលរួម និងចំនួនយានជំនិះតាមប្រភេទនីមួយៗ។



សំណួរ និងចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធ

ជារួម ការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយត្រូវធ្វើឡើងឱ្យស្របតាមនីតិវិធី និងសេចក្ដីណែនាំពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត។

ឯកឧត្តម **ឌឹម សុវណ្ណារុំ** បានបញ្ជាក់ជូនទៀតថា ការឃោសនាបោះឆ្នោត ត្រូវតែមានការរក្សាសន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ។ ដើម្បីចូលរួមការពារក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ឱ្យដំណើរការប្រកបដោយបរិយាកាសសន្តិសុខ សណ្ដាប់ធ្នាប់-សាធារណៈ និងសុវត្ថិភាព គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សា គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានដាក់ចេញនូវសេចក្ដីណែនាំរួមលេខ ០១ ស.ណ.ន ចុះថ្ងៃទី៣១ ខែមករា



សកម្មភាពក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ

ឆ្នាំ២០២៣ ស្ដីពី "សកម្មភាព និងការរៀបចំភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងយុទ្ធនាការការពារដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣" ដើម្បីកំណត់យន្តការ/រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតគ្រប់លំដាប់ថ្នាក់ក្រសួង/ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ជាពិសេសគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ព្រមទាំងភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់ ឱ្យយកចិត្តទុកដាក់សហការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងបានរៀបចំកម្លាំងការពារយុទ្ធនាការឃោសនាបោះឆ្នោត។ ឯកឧត្តមបានបន្តថា គោលដៅការពារការឃោសនាបោះឆ្នោតគឺស្ថិតនៅទាំង ១.៦៥២ ឃុំ សង្កាត់ ចាប់ពីថ្ងៃទី១ រហូតដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ ហើយកម្លាំងដែលត្រូវប្រើប្រាស់រួមមាន៖

- ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់
- អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ មូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌ និង



សំណួរ និងចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធ



**សំណួរ និងចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធ**

- ផ្នែកសឹករងក្រុង ស្រុក ខណ្ឌ ដែលមានកម្លាំងសរុប ចំនួន ១៩.៧២៤ នាក់។

អំពីនីតិវិធីនៃការការពារសន្តិសុខក្នុងពេលឃោសនាបោះឆ្នោត ឯកឧត្តម **ឌឹម សុវណ្ណារុំ** បានជម្រាបជូនថា ភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវបានចាត់ចែងកម្លាំងការពារក្បួនព្យុហ-យាត្រា ឬក្បួនដំណើរដោយថ្មើរជើង ឬយានជំនិះគ្រប់ប្រភេទ និងជុំវិញបរិវេណនៃការជួបជុំ ឬការឃោសនាជាសាធារណៈ ដោយរក្សាឱ្យបាននូវបរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការបំភិតបំភ័យ ការគំរាមកំហែង និងគ្មានអំពើហិង្សា ឬបង្កការអុកឡុក ការរំខាន ឬចលាចលណាមួយ និងការរៀបចំសណ្តាប់ធ្នាប់របៀបរៀបរយ សម្រាប់គ្រប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនគ្រប់ៗរូប។ ភ្នាក់ងារសន្តិសុខបោះឆ្នោត មិនត្រូវទៅឈរក្បែរ ឬដើរកៀកពេកទៅនឹងទីតាំង ឬក្បួនឃោសនាបោះឆ្នោត ឬស្ថិតនៅក្នុងបរិវេណនៃអង្គពិធីឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយឡើយ។

ចំពោះការគោរពច្បាប់ចរាចរណ៍ ឯកឧត្តម **ឌឹម សុវណ្ណារុំ** បានបញ្ជាក់ជូនថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក៏បានដាក់ចេញនូវសេចក្តីណែនាំលេខ ០៣៧ គ.ជ.ប ស.ណ.ន ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ ស្តីពីការហែក្បួនឃោសនាបោះឆ្នោត និងការធ្វើសកម្មភាពចែកខិត្តបណ្ណនៅក្នុងផ្សាររបស់គណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ផងដែរ ដើម្បីកំណត់ទម្រង់ និងទំហំនៃការហែក្បួនឃោសនាបោះឆ្នោត ក្នុងគោលបំណងធ្វើយ៉ាងណាឱ្យគណបក្សនយោបាយយកចិត្តទុកដាក់គោរព និងរក្សាឱ្យបាននូវសណ្តាប់ធ្នាប់ល្អ តាមដងផ្លូវ ទីប្រជុំជន តាមទីសាធារណៈ និងយកចិត្តទុកដាក់គោរពច្បាប់ចរាចរណ៍ផ្លូវគោក។



**ចំណាប់អារម្មណ៍ និងសំណួររបស់ភាគីពាក់ព័ន្ធ**



**សំណួរ និងចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធ**

ក្នុងកិច្ចប្រជុំនោះមានចំណាប់អារម្មណ៍ និងសំណួររបស់ភាគីពាក់ព័ន្ធផ្តោតលើការការពារសន្តិសុខ សុវត្ថិភាពក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ដែលជាបច្ចេកទេស និងនីតិវិធីនៃការការពារនោះធ្វើឡើងដូចម្តេច?

តំណាង គ.ជ.ប បានបញ្ជាក់ជូនទៅតាមនីតិវិធី និងបានលើកយកសេចក្តីណែនាំរួមរវាង គ.ជ.ប ជាមួយក្រសួងមហាផ្ទៃ លេខ ០១ ស.ណ.ន ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ ស្តីពីសកម្មភាព និងការរៀបចំភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងយុទ្ធ-នាការការពារដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។ ជាមួយគ្នានេះ គ.ជ.ប សូមឱ្យគណបក្សនយោបាយធ្វើការទំនាក់ទំនងដោយផ្ទាល់ជាមួយគណៈ-កម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត និងគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ពាក់ព័ន្ធនឹងការការពារសន្តិសុខ

សណ្តាប់ធ្នាប់ក្នុងពេលធ្វើសកម្មភាពឃោសនាបោះឆ្នោត។

ក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធនឹងការបោះឆ្នោតនេះ មានការអញ្ជើញចូលរួមពីតំណាង ក្រុមប្រឹក្សាធម្មនុញ្ញ ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន ក្រសួងការពារជាតិ គណបក្សនយោបាយ តំណាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មន្ត្រីស្ថានទូតអូស្ត្រាលី មន្ត្រីស្ថានទូតជប៉ុន មន្ត្រីស្ថានទូតរុស្ស៊ី និងអ្នកសារព័ត៌មាន ចំនួនប្រមាណ ៧០ នាក់៕

# គ.ជ.ប ដាក់បង្ហាញ និងធ្វើតេស្តទឹកខ្មៅលុបមិនជ្រះ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

នាព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ១០:០០ នៅសាលសន្និសីទរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានរៀបចំកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ ក្រោមអធិបតីភាព ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំ ដើម្បីបង្ហាញទឹកខ្មៅលុបមិនជ្រះ ដែលត្រូវប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសាកល្បងគុណភាពទឹកខ្មៅនេះជូនដល់ភាគីពាក់ព័ន្ធ។



ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប

ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានជម្រាបជូនអំពីគោលការណ៍នៃការប្រើប្រាស់ទឹកខ្មៅលុបមិនជ្រះនេះថា ផ្អែកតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ទឹកខ្មៅលុបមិនជ្រះដែលអាចមើលឃើញច្បាស់ ត្រូវបានដាក់បញ្ញត្តិឱ្យប្រើក្នុងការបោះឆ្នោត សម្រាប់បង្ការការបោះឆ្នោតលើសពីមួយដង ពីព្រោះថាគោលការណ៍នៃការបោះឆ្នោតនៅកម្ពុជា ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត គឺបោះឆ្នោតបានតែមួយសន្លឹកប៉ុណ្ណោះ។ ឯកឧត្តមបានបន្តថា មិនខុសពីការបោះឆ្នោតនីតិកាលមុនៗ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣នេះ គ.ជ.ប នៅតែបន្តរក្សាការប្រើប្រាស់ទឹកខ្មៅលុបមិនជ្រះរបស់ក្រុមហ៊ុន MYSORE PAINTS & VARNISH LTD. នៃប្រទេសឥណ្ឌា ដែលជាក្រុមហ៊ុនមានឯកទេសក្នុងការផលិតទឹកខ្មៅនេះ និងធ្លាប់បានផ្គត់ផ្គង់ជូន គ.ជ.ប រៀងរាល់ការបោះឆ្នោត ហើយក៏មានប្រទេសជាង ៣០ នៅលើសកលលោក បានប្រើប្រាស់ទឹកខ្មៅរបស់ក្រុមហ៊ុននេះ ដែលមានដូចជា ឥណ្ឌា (ខ្លួនឯង) កម្ពុជា ម៉ាឡេស៊ី នេប៉ាល់ អាហ្វ្រិកខាងត្បូង ប៉ាគីស្ថាន និងអាហ្គានីស្ថាន។ល។



តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានជម្រាបជូនបន្តទៀតថា មុននឹងធ្វើការបញ្ជាផលិតជាផ្លូវការ នៅក្នុងចុងខែធ្នូ ឆ្នាំ២០២២ កន្លង



**សកម្មភាពភាគីពាក់ព័ន្ធធ្វើតេស្តទឹកខ្មៅលុបមិនជ្រះ**

មកនេះ គ.ជ.ប បានស្នើសុំគំរូទឹកខ្មៅលុបមិនជ្រះដើម្បីសាកល្បងគុណភាពជាមុនពីក្រុមហ៊ុន មានចំនួន ៤ កម្រិត គឺ៖

- កម្រិតសូលុយស្យុងប្រាក់នីត្រាត ២៥%
- កម្រិតសូលុយស្យុងប្រាក់នីត្រាត ២០%
- កម្រិតសូលុយស្យុងប្រាក់នីត្រាត ១៨%
- កម្រិតសូលុយស្យុងប្រាក់នីត្រាត ១៥%។

ឯកឧត្តមប្រធាន គ.ជ.ប បានបន្តទៀតថា មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប បានធ្វើការសាកល្បងគំរូទឹកខ្មៅលុបមិនជ្រះដែលក្រុមហ៊ុនបានផ្តល់ជូន ចំនួន ៤ កម្រិតនេះ ឃើញថា ទឹកខ្មៅលុបមិនជ្រះកម្រិតសូលុយស្យុងប្រាក់នីត្រាត ២០% មានគុណភាពល្អ ជាពិសេសភាពជិតខ្មៅជាប់នឹងស្បែកដៃ ក្រចក និងគល់ក្រចក ព្រមទាំងកម្រិតស្ងួតលឿនក្នុងបរិយាកាសមិនអាចលុបជ្រះភ្លាមៗបានឡើយ ហើយគុណភាពនេះប្រហាក់ប្រហែលនឹងគុណភាពទឹកខ្មៅលុបមិនជ្រះដែល គ.ជ.ប បានប្រើប្រាស់ក្នុងការបោះឆ្នោតកន្លងមក ដែលអាចធានាបានទាំងគុណភាពប្រើប្រាស់ និងអាចធានាបានទាំងសុខភាពរបស់



**សកម្មភាពភាគីពាក់ព័ន្ធធ្វើតេស្តទឹកខ្មៅលុបមិនជ្រះ**

អ្នកប្រើប្រាស់។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានបញ្ជាក់ទៀតថា នៅក្នុងខែកុម្ភៈ ឆ្នាំ២០២៣ គ.ជ.ប បានធ្វើការបញ្ជាផលិតជាផ្លូវការទៅក្រុមហ៊ុននៃប្រទេសឥណ្ឌានូវទឹកខ្មៅលុបមិនជ្រះកម្រិតសូលុយស្យុងប្រាក់នីត្រាត ២០% ចំនួនសរុប ៥២.០០០ ដប ក្នុង ១ ដប ចំណុះ ៧០ មីលីលីត្រ ដោយដបនីមួយៗរចនារាងខ្លីជាងមុន និងមានអេប៉ុងខាងក្នុងដប ដើម្បីឱ្យអ្នកបោះឆ្នោតងាយស្រួលក្នុងការជ្រលក់ម្រាមដៃ។ ក្នុងគោលបំណងត្រួតពិនិត្យឱ្យកាន់តែច្បាស់លាស់ នៅក្នុងខែមេសា ឆ្នាំ២០២៣ គ.ជ.ប ក៏បានចាត់តាំងមន្ត្រីជំនាញទៅចូលរួមសង្កេតមើលខ្សែសង្វាក់ផលិតកម្មទឹកខ្មៅនេះ នៅទីតាំងក្រុមហ៊ុនឯប្រទេសឥណ្ឌាផ្ទាល់តែម្តង។ ទឹកខ្មៅលុបមិនជ្រះនេះ មានសុពលភាព ៦ ខែ គិតបន្ទាប់ពីការ



**សំណួរ និងចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធ**

ផលិត (កាលបរិច្ឆេទប្រើចុងក្រោយ ខែវិច្ឆិកា ឆ្នាំ២០២៣)។ ឯកឧត្តមបានបន្ថែមថា ទឹកខ្មៅលុបមិនជ្រះនេះ ត្រូវបានបែងចែកតាមគោលដៅប្រើប្រាស់ដូចតទៅ៖

- ផ្តល់ជូនក្នុងមួយការិយាល័យបោះឆ្នោតចំនួន ២ ដប
- បម្រុងរក្សាទុកនៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គជ.ខប) ចំនួន ៨០០ ដប ដើម្បីដោះស្រាយពេលមានតម្រូវការចាំបាច់ និង
- រក្សាទុកនៅ គ.ជ.ប មួយចំនួន។

ការចំណាយថវិកាសរុបមានចំនួន ៩៦៣.៣១០ ដុល្លារ ដែលក្នុង ១ ដប ថ្លៃ ១៧,៦៣ ដុល្លារ សរុបជាទឹកប្រាក់ចំនួន ៩១៦.៧៦០ ដុល្លារ បូកនឹងតម្លៃសេវាដឹកជញ្ជូន រួមទាំងការធានារ៉ាប់រង ៤៦.៥៥០ ដុល្លារ។

មានចំណាប់អារម្មណ៍ និងសំណួររបស់ភាគីពាក់ព័ន្ធ ដែលចូលរួមក្នុងពិធីនោះ ជុំវិញការប្រើប្រាស់ទឹកខ្មៅលុបមិនជ្រះនេះ។ អ្នកចូលរួមបានសរសើរដល់ គ.ជ.ប ថា ទឹកថ្នាំនេះមានគុណភាពល្អ ដែល គ.ជ.ប បានប្រើប្រាស់លើកនេះ ក៏ដូចជាប្រើប្រាស់សម្រាប់ការបោះឆ្នោតកន្លងមក ដែលគ្មានជនណាម្នាក់អាចបន្លំបោះឆ្នោតបានលើសពីមួយដងឡើយ និងមានសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងការប្រើប្រាស់ទឹកខ្មៅលុបមិនជ្រះជ្រលក់ដៃសម្រាប់ការបោះឆ្នោត។

គ.ជ.ប បានបញ្ជាក់ជូនថា សម្រាប់ការបោះឆ្នោតឆ្នាំ២០២៣ នេះ គ.ជ.ប មានវិធានការគ្រប់គ្រាន់ចំពោះជនដែលឃោសនាមិនពិតអំពីទឹកខ្មៅជ្រលក់ដៃនេះ។ វិធានការបង្ការមិនឱ្យបោះឆ្នោតលើសពីមួយដង មិនមែនមានតែការប្រើទឹកខ្មៅលុបមិនជ្រះប៉ុណ្ណោះទេ គ.ជ.ប មានវិធានការជាច្រើនទៀត



**សំណួរ និងចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធ**

ដូចជា៖ ការតម្រូវឱ្យលេខាធិការយកចិត្តទុកដាក់ផ្ទៀងផ្ទាត់អត្តសញ្ញាណ គូសសញ្ញាធិកត្រង់ឈ្មោះអ្នកបោះឆ្នោតដែលបានអញ្ជើញមកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ដើម្បីសម្គាល់ថា អ្នកបោះឆ្នោតនោះបានបោះឆ្នោតរួច កិច្ចដំណើរការទាំងអស់ត្រូវបានដាក់ឱ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យពីភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នៅក្នុងការិយាល័យបោះឆ្នោត។ល។ ម្យ៉ាងទៀត គ.ជ.ប បានប្រើប្រាស់ទឹកខ្មៅជ្រលក់ដៃសម្រាប់រៀបចំការបោះឆ្នោតជាសកលនេះ ៦ លើករួចមកហើយ ពុំទាន់មានជនណាម្នាក់បន្លំខ្លួនមកបោះឆ្នោត ២ ដងនោះទេ។ ករណីនេះ ប្រសិនបើមាននោះ គ.ជ.ប នឹងចាត់វិធានការតាមច្បាប់។

បន្ទាប់ពីឆ្លើយនឹងសំណួរចប់សព្វគ្រប់ គ.ជ.ប បាន



**គណៈអធិបតីក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ**

អញ្ជើញភាគីពាក់ព័ន្ធទាំងអស់សាកល្បងជ្រលក់កូនដៃទៅនឹងទឹកខ្មៅលុបមិនជ្រះ។ បន្ទាប់ពីជ្រលក់ម្រាមដៃឆ្វេងរួចមក អ្នកដែលបានសាកល្បងនោះ មានចំនួន ២៥ នាក់ ហើយបានបង្ហាញចំណាប់អារម្មណ៍ទទួលស្គាល់ថា ទឹកខ្មៅ ដែលប្រើប្រាស់សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះ គឺនៅតែមានគុណភាពល្អដូចការប្រើប្រាស់សម្រាប់ការបោះឆ្នោតកន្លងមកដែរ ហើយសរសើរដល់ គ.ជ.ប ដែលបានរៀបចំចាត់ចែងការបោះឆ្នោតនេះប្រកបដោយតម្លាភាពក្នុងពិធីបង្ហាញទឹកខ្មៅលុបមិនជ្រះ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតនេះ។

ក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធនឹងការបោះឆ្នោតនេះ មានការអញ្ជើញចូលរួមពីតំណាង ក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន អគ្គស្នងការដ្ឋាននគរបាលជាតិ ស្ថានទូតឥណ្ឌា គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មាន ចំនួនប្រមាណ ១០០ នាក់៕



**សំណួរ និងចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធ**

# ស្ថានភាពទូទៅនៃការឃោសនាបោះឆ្នោត រយៈពេល ១០ ថ្ងៃ

នាព្រឹកថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ១០:០០ នៅសាលសន្និសីទរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានរៀបចំកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធក្រោមអធិបតីភាព ឯកឧត្តម **ហ៊ែល សារ៉ាត់** សមាជិក គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំ ដើម្បីផ្សព្វផ្សាយអំពីសភាពការណ៍ទូទៅនៃដំណើរការឃោសនាបោះឆ្នោត បណ្ដឹងពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត និងការការពារសន្តិសុខនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត នៅក្នុងដំណើរការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។



តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ

ឯកឧត្តម **ហ៊ែល សារ៉ាត់** សមាជិក គ.ជ.ប បានជម្រាបជូនអំពីសកម្មភាពឃោសនារបស់គណបក្សនយោបាយថា ក្នុងរយៈពេល ១០ ថ្ងៃ កន្លងមកនេះ គណបក្សនយោបាយនីមួយៗ បានធ្វើសកម្មភាពឃោសនាបោះឆ្នោតតាមមធ្យោបាយផ្សេងៗ និងតាមលទ្ធភាពរៀងៗខ្លួន ដែលសកម្មភាពទាំងនោះមានដូចជាការជួបប្រជុំជាមួយអ្នកគាំទ្រ និងសកម្មជននៅតាមទីសាធារណៈ និងតាមទីស្នាក់ការគណបក្សនយោបាយ ការចុះសួរសុខទុក្ខប្រជាពលរដ្ឋតាមខ្នងផ្ទះ ការប្រគំតន្ត្រី ការបញ្ចាំងស្លាយវីដេអូតាមទីសាធារណៈ ការចែកខិត្តបណ្ណតាមខ្នងផ្ទះ និងតាមផ្សារ ការចាក់មេក្រូផ្សព្វផ្សាយនៅតាមទីស្នាក់ការគណបក្សនយោបាយ និងចាក់ចល័តតាមភូមិជាដើម។ លើសពីនេះក៏មានការផ្សព្វផ្សាយ



ឯកឧត្តម ហ៊ែល សារ៉ាត់ សមាជិក គ.ជ.ប

នូវសកម្មភាពឃោសនាបោះឆ្នោត និងសារនយោបាយរបស់គណបក្សនយោបាយនៅលើបណ្ដាញព័ត៌មានសង្គមហ្វេសប៊ុក (FACEBOOK) ជារៀងរាល់ថ្ងៃផងដែរ។

ឯកឧត្តម **ហ៊ែល សារ៉ាត់** បានជម្រាបជូនបន្ថែមទៀតថា ក្នុងចំណោមគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតទាំង ១៨ មានគណបក្សចំនួន ១៥ បានធ្វើសកម្មភាពហែក្បួនឃោសនាបោះឆ្នោត នៅតាមមណ្ឌលបោះឆ្នោតនានាដែលខ្លួនមានបញ្ជីបេក្ខជនឈរឈ្មោះ។ គ្រប់គណបក្សនយោបាយបានជូនដំណឹងទៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) អំពីពេលវេលា និងទីតាំងដែលពួកគេត្រូវធ្វើសកម្មភាពឃោសនា។ អាជ្ញាធរមូលដ្ឋានបានខិតខំជួយសម្របសម្រួលដល់ការធ្វើសកម្មភាពឃោសនាបោះឆ្នោត ការការពារទីតាំងឃោសនាបោះឆ្នោត រក្សាសន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ



តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ

ពិសេសបានជួយសម្រួលចរាចរណ៍តាមដងផ្លូវនៅពេលមានការហែក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ។

ឯកឧត្តម **ហ៊ែល សារ៉ាត់** បានជម្រាបជូនបន្ថែមទៀតថា ក្នុងអំឡុងពេលនៃការឃោសនារកសំឡេងឆ្នោតនេះផងដែរ គណបក្សនយោបាយទាំង ១៨ មានឱកាសផ្សព្វផ្សាយដោយស្មើភាពគ្នា នូវគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួន ទៅកាន់អ្នកបោះឆ្នោតតាមរយៈកម្មវិធីផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយ ដែលរៀបចំដោយ គ.ជ.ប។ ការផ្សព្វផ្សាយនេះធ្វើឡើងតាមវិទ្យុ និងទូរទស្សន៍របស់រដ្ឋ។



**តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ**

ឯកឧត្តម **ហ៊ែល សារ៉ាត់** បានវាយតម្លៃថា ដំណើរការនៃការឃោសនាបោះឆ្នោតមកទល់ថ្ងៃទី១១ នេះ បានប្រព្រឹត្តទៅដោយរលូន មានការយោគយល់អធ្យាស្រ័យគ្នាខ្ពស់ មានកិច្ច-សហការពីបណ្តាភាគីពាក់ព័ន្ធនានាបានល្អប្រសើរ ដែលរក្សាបាននូវសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់របៀបរៀបរយក្នុងមណ្ឌលបោះឆ្នោតនីមួយៗ។

ពាក់ព័ន្ធនឹងបណ្តឹង ឯកឧត្តម **ហ៊ែល សារ៉ាត់** បានជម្រាបជូនថា បណ្តឹងពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត គិតត្រឹមថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ គ.ជ.ប បានទទួលពាក្យបណ្តឹងសរុបចំនួន ២ បណ្តឹង គឺពាក្យបណ្តឹងនៅគណៈកម្មការរៀបចំការបោះឆ្នោតឃុំទួលពង្រ នៃខេត្តបន្ទាយមានជ័យ។ ករណីនេះ គណៈកម្មការរៀបចំការបោះឆ្នោតឃុំទួលពង្រ បានបើកកិច្ចប្រជុំផ្សះផ្សា កាលពីថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣ ដោយគូភាគីមិនព្រមសះជាឡើយ។ ក្រោយពីថ្ងៃផ្សះផ្សាមិនសះជា ភាគីទំនាស់មិនបានដាក់ពាក្យបណ្តឹងបន្តទៅគណៈកម្មការរៀបចំ



**សកម្មភាពក្នុងកិច្ចប្រជុំភាគីពាក់ព័ន្ធ**

ការបោះឆ្នោតខេត្តបន្ទាយមានជ័យឡើយ ហើយបើគិតមកដល់ពេលនេះ គឺហួសអាជ្ញាយុកាលនៃការប្តឹងទៅហើយ។ ពាក្យបណ្តឹងមួយទៀត កើតឡើងនៅគណៈកម្មការរៀបចំការបោះឆ្នោតសង្កាត់ភ្នំពេញថ្មី នៃរាជធានីភ្នំពេញ។ ករណីនេះ គណៈកម្មការរៀបចំការបោះឆ្នោតសង្កាត់ភ្នំពេញថ្មី បានធ្វើលិខិតជូនដំណឹងតាមលិខិតរដ្ឋបាលទៅភាគីដើមបណ្តឹងរួចហើយ។

អំពីការការពារសន្តិសុខនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ឯកឧត្តម **ហ៊ែល សារ៉ាត់** បានជម្រាបជូនថា គ្រប់ការិយាល័យបោះឆ្នោត និងគ្រប់ការិយាល័យរាប់សន្លឹកឆ្នោត គឺជាទីតាំងរដ្ឋបាល និងសន្តិសុខ ដែលត្រូវមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ។ បរិវេណខាងក្នុង គឺជាតំបន់ដែលនៅជុំវិញការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ហើយខណ្ឌដោយវណ្ឌមណ្ឌលមួយមានកាំប្រវែងយ៉ាងតិច ១៥ (ដប់ប្រាំ) ម៉ែត្រ។ បរិវេណខាងក្នុងត្រូវរៀបចំឱ្យមានច្រកចូលមួយ និងច្រកចេញមួយ។ បរិវេណខាងក្រៅគឺជាតំបន់ដែលនៅជុំវិញការិយាល័យបោះឆ្នោត និងការិយាល័យ



**តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ**

រាប់សន្លឹកឆ្នោត ដែលខណ្ឌដោយរង្វង់មណ្ឌលមានកាំប្រវែង ១០០ (មួយរយ) ម៉ែត្រ ឬតូចជាង អាស្រ័យដោយស្ថានភាពទីតាំងជាក់ស្តែង ឬមានទម្រង់ផ្សេងពីនេះ ដូចជាបរិវេណរបងនៃសាលារៀន វត្តអារាម សាលមហោស្រព ឬទីសាធារណៈជាដើម។ នៅតំបន់ទីប្រជុំជន បរិវេណខាងក្រៅត្រូវកំណត់ដោយ គ.ជ.ប ដោយយោងលើការវាយតម្លៃអំពីស្ថានភាពសន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងតំបន់នោះ។ ក្នុងករណីការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតមួយ តាំងនៅប្រមាណ ១០០ (មួយរយ) ម៉ែត្រ ពីការិយាល័យបោះឆ្នោតពាក់ព័ន្ធមួយផ្សេងទៀត មួយផ្នែកនៃផ្លូវនេះត្រូវតែបិទចរាចរណ៍។

ឯកឧត្តម **ហ៊ែល សារ៉ាត់** បានមានប្រសាសន៍បន្តទៀតថា ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនោះឱ្យជៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខាន អុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងដើម្បីរក្សាការពារឧបករណ៍ សម្ភារ ឯកសារបោះឆ្នោតទាំងអស់ក្នុងការិយាល័យទាំងនោះ គ.ជ.ប គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ជាពិសេសគណៈកម្មការការិយាល័យបោះឆ្នោត/គណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ត្រូវចាត់វិធានការចាំបាច់នានា ដូចបានចែងក្នុងបទបញ្ញា និងនីតិវិធី។

ក្នុងនាម គ.ជ.ប ឯកឧត្តម **ហ៊ែល សារ៉ាត់** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបណ្តាភាគីពាក់ព័ន្ធទាំងអស់ មានគណបក្សនយោបាយ ដែលបានចូលរួមសហការផ្តល់ព័ត៌មាន និងគោរពតាមការរៀបចំចាត់ចែងនិងសម្របសម្រួលពីអាជ្ញាធរ និងគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ហើយគោរពបាននូវក្រមសីលធម៌ក្នុងការឃោសនាបោះឆ្នោត។ អាជ្ញាធររាជធានី ខេត្ត បានផ្តល់កិច្ចសហការ ជួយសម្របសម្រួល រក្សាសន្តិសុខ សុវត្ថិភាព និងរក្សាសណ្តាប់ធ្នាប់ដោយពុំមានការរើសអើង។ គ.ជ.ប សូមលើកទឹកចិត្តបន្តទៀតដល់មន្ត្រីរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំបំពេញតួនាទី ភារកិច្ចស្របតាមច្បាប់ បទបញ្ញា និងនីតិវិធី ក្រមសីលធម៌ ព្រមទាំងសេចក្តីណែនាំនានាបានយ៉ាងខ្ជាប់ខ្ជួន។

ក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធនឹងការបោះឆ្នោតនេះ មានការអញ្ជើញចូលរួមពីតំណាង ក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន អគ្គស្នងការដ្ឋាននគរបាលជាតិ មន្ត្រីស្ថានទូតជប៉ុន ស្ថានទូតស្វីស គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្រុមប្រឹក្សាសកម្មភាពជនពិការ និងអ្នកសារព័ត៌មាន ចំនួនប្រមាណ ៦០ នាក់៕

# អ្នកណែនាំឱ្យប្រជាពលរដ្ឋគូសសន្លឹកឆ្នោតចោលនៅពេលទៅបោះឆ្នោត នឹងត្រូវផ្តន្ទាទោសតាមច្បាប់

ថ្ងៃបោះឆ្នោតកាន់តែខិតជិតមកដល់នេះ ក្រុមប្រតិកម្មព័ត៌មាន គ.ជ.ប បានកត់សម្គាល់ឃើញថាមានបុគ្គលមួយចំនួនកាន់តែបន្តយុទ្ធនាការតាមបណ្តាញព័ត៌មានសង្គម ដោយណែនាំឱ្យប្រជាពលរដ្ឋគូសសន្លឹកឆ្នោតចោលពេលទៅបោះឆ្នោត នៅថ្ងៃបោះឆ្នោត ដើម្បីធ្វើឱ្យសន្លឹកឆ្នោតរបស់ពួកគាត់ ក្លាយជាសន្លឹកឆ្នោតមិនបានការ ដោយហេតុថាគ្មានគណបក្សភ្លើងទៀន។ អ្នកណែនាំបែបនេះនឹងត្រូវផ្តន្ទាទោសតាមច្បាប់ដែលមានជាធរមាន។

មាត្រា ១៤២ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចែងថា ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន)រៀល ដោយ គ.ជ.ប ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។

- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។

ចំពោះជនដែលបានប្រព្រឹត្តល្មើសណាមួយដូចបានដកស្រង់ខាងលើនេះ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច បន្ថែមទៀត ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ផ្ទុយទៅវិញ គ.ជ.ប សូមអំពាវនាវ សូមប្រជាពលរដ្ឋ កុំចាញ់បោកទង្វើទុច្ចរិតរបស់ជនអគតិមួយចំនួន ដែលមានចេតនាបំផ្លាញលទ្ធិប្រជាធិបតេយ្យ បំផ្លាញសិទ្ធិបងប្អូន និងនាំបងប្អូនឱ្យប្រព្រឹត្តអំពើផ្ទុយនឹងច្បាប់។

គ.ជ.ប សូមអំពាវនាវប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២២ ទាំងអស់ មេត្តាត្រៀមខ្លួន និងត្រៀមអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) ដើម្បីចូលរួមបោះឆ្នោតនៅថ្ងៃបោះឆ្នោត គឺថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ឱ្យបានគ្រប់ៗគ្នា។

គ.ជ.ប សូមលើកទឹកចិត្តម្ចាស់ឆ្នោត សូមគូសសញ្ញាធិក (√) គាំទ្រគណបក្សនយោបាយដែលខ្លួនស្រឡាញ់ពេញចិត្ត ហើយការចូលរួមគូសសន្លឹកឆ្នោតឱ្យបានត្រឹមត្រូវ ដូចដែលប្រជាពលរដ្ឋកម្ពុជាធ្លាប់មានបទពិសោធន៍បោះឆ្នោតជាច្រើនលើក ច្រើនសារួចមកហើយ គឺជាការបញ្ជាក់ឡើងវិញ ដូចមានចែងក្នុងបុព្វកថានៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ***"យើង ប្រជារាស្ត្រខ្មែរ បានធ្លាក់លើក ក្រោកឈរឡើង ចងបាច់ធន្ទះមោះមុត ប្តូរផ្តាច់ រួបរួមគ្នា ពង្រឹងឯកភាពជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យថ្លៃថ្លា និងអារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឱ្យទៅជា "កោះសន្តិភាព" ឡើងវិញ ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវចំពោះវាសនាអនាគតជាតិ ឱ្យបានឈានឡើងរីកចម្រើន លូតលាស់ សម្បូររុងរឿងជានិច្ចនិរន្តរ៍"***។

---

# បម្រាមចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

ត្រូវបានហាមឃាត់ ចំពោះសកម្មភាពដែលត្រូវបានចាត់ទុកថា ជាការរំលោភធ្ងន់ធ្ងរខាងផ្នែកវិជ្ជាជីវៈអ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដូចខាងក្រោម៖

- ការផ្សព្វផ្សាយព័ត៌មានដែលធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត
- ការបង្ខំឱ្យគេយល់ខុសដូចជា ការសរសេរបញ្ចិតបញ្ចៀងដើម្បីឱ្យសាធារណជនមានការសង្ស័យដោយអយុត្តិធម៌លើបុគ្គលណាម្នាក់ ក្រុមបក្សណាមួយ
- ការផ្សព្វផ្សាយព័ត៌មានដោយសំអាងលើពាក្យចចាមអារ៉ាម ឬព័ត៌មានដែលពុំមានភស្តុតាងបញ្ជាក់
- ការផ្សព្វផ្សាយដែលមានលក្ខណៈមួលបង្កាច់ បរិហារកេរ្តិ៍ និងជេរប្រមាថដល់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ
- ការប្រើប្រាស់ភាសាញុះញង់ ឬវាយប្រហារ ដែលអាចបង្កភាពគ្មានសណ្តាប់ធ្នាប់ ឬអាចឱ្យមានអំពើហិង្សា
- ការបោះពុម្ពផ្សាយ ឬចែកចាយព័ត៌មានណាដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបង្កឱ្យមានការភ័យខ្លាច ឬបង្កជាអំពើហិង្សាណាមួយកើតឡើង
- ការផ្សព្វផ្សាយព័ត៌មានដែលញុះញង់ឱ្យមានការរើសអើង ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើត

ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀត
- ការបោះពុម្ពផ្សាយ ឬផ្សាយបន្តនូវព័ត៌មានដែលបណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខជាតិ ស្ថិរភាពនយោបាយ និងស្ថិរភាពសង្គម
- ការបោះពុម្ពផ្សាយ ឬផ្សាយបន្តហេតុការណ៍ ឬព្រឹត្តិការណ៍មិនពិតដែលជាការជេរប្រមាថ ការមើលងាយដល់ស្ថាប័នជាតិ
- ការផ្សព្វផ្សាយមានលក្ខណៈរើសអើង ប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
- ការសម្តែងចេញនូវនិន្នាការនយោបាយ ការមាក់ងាយ ឬការប្រមាថ តាមរយៈកាយវិការ ឬឥរិយាបថជាក់ស្តែងផ្សេងទៀត
- ការបញ្ចេញបញ្ចូលនូវទស្សនៈផ្ទាល់ខ្លួន ឬក៏ធ្វើបុរេវិនិច្ឆ័យ នៅក្នុងហេតុការណ៍កំពុងកើតមានដែលខ្លួនធ្វើសេចក្តីរាយការណ៍
- ការជ្រៀតជ្រែក ឬរំខានដល់ការងារចុះឈ្មោះបោះឆ្នោត បោះឆ្នោត និងរាប់សន្លឹកឆ្នោត
- ការផ្សព្វផ្សាយមិនឱ្យប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោត
- ការទទួលសំណូក អំណោយក្នុងបែបណាមួយ ឬការជំរិតយកប្រាក់ ដើម្បីជាថ្នូរនឹងការផ្សព្វផ្សាយ ឬមិនផ្សព្វផ្សាយនូវព័ត៌មានណាមួយ
- ការធ្វើសម្ភាសន៍នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការប្រើប្រាស់តួនាទីរបស់ខ្លួន (ទោះឯកជន ឬរដ្ឋ) ដើម្បីគាបសង្កត់លើមន្ត្រីចុះឈ្មោះបោះឆ្នោត ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) មន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬគាបសង្កត់លើអ្នកសង្កេតការណ៍ ឬបេក្ខជន ឬភ្នាក់ងារគណបក្សនយោបាយ ឬអ្នកមានសិទ្ធិបោះឆ្នោត ឬអ្នកបោះឆ្នោតឡើយ
- ត្រូវចៀសវាងការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត និងការគូសឈើគូសកេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ
- មិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្ត នៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត៕

---

## បម្រាមចំពោះអ្នកសង្កេតការណ៍ ក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

ក្នុងការសង្កេតមើលការឃោសនាបោះឆ្នោត និងរាល់សកម្មភាពនានានៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត នៅមុនពេល ក្នុងពេល និងក្រោយពេលនៃការបោះឆ្នោត អ្នកសង្កេតការណ៍មិនត្រូវ៖

- ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃព្រះរាជាណាចក្រកម្ពុជា
- ជជែកពិភាក្សាទាក់ទងនឹងបញ្ហាគាំទ្រ ឬប្រឆាំងគណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោតណាមួយ ជាមួយនឹងអ្នកបោះឆ្នោត
- យកតាមខ្លួននូវគ្រឿងអាវុធ ជាតិផ្ទុះ ឬវត្ថុដែលអាចបង្កឱ្យមានគ្រោះថ្នាក់ក្នុងអំឡុងពេលបំពេញភារកិច្ចសង្កេតការណ៍របស់ខ្លួន
- បញ្ចុះបញ្ចូល ឬប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួម

ឃោសនាដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់

- ចូលរួមក្នុងក្បួនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
- ចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
- ចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ
- ស្ទង់មតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
- សរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
- និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
- និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យប្រមាថមាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
- ដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗ ភ្ជាប់នឹងយានយន្តរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
- ផ្តល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
- ផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋ សម្រាប់ចូលរួមក្នុងសកម្មភាពឃោសនាដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
- ផ្តល់ថវិកា សម្ភារ និងបរិក្ខារសម្រាប់ដង្ហែក្បួនឃោសនា ការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនា ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
- រំខាន ឬជ្រៀតជ្រែកក្នុងកិច្ចការផ្សេងៗរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ណាមួយនៅពេលដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតកំពុងប្រព្រឹត្តទៅ
- ប៉ះពាល់ឯកសារ ឬសម្ភារ បរិក្ខារបោះឆ្នោត ក្នុងនោះរួមទាំងសន្លឹកឆ្នោតផង
- ប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរសព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗ នៅក្នុងការិយាល័យបោះឆ្នោត
- នៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត
- ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត និងបង្អាក់ដំណើរការបោះឆ្នោត
- រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់បោះឆ្នោត ឬបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត
- ចូលរួមជជែកវែកញែកក្នុងដំណើរការដោះស្រាយបណ្តឹងណាមួយក្នុងអំឡុងពេលបោះឆ្នោត ប៉ុន្តែអាចសង្កេតការណ៍លើការដោះស្រាយបណ្តឹងនេះបាន
- ត្រូវចៀសវាងការដក់បារីនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត និងការគូសឈើគូសកេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ
- មិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០០៤ គ.ជ.ប. ស.អ.ន

# សេចក្តីអំពាវនាវ

**ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣** ខាងមុខនេះ គឺជាថ្ងៃដែលប្រជាពលរដ្ឋត្រូវទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧។ អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២២ មានសិទ្ធិបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

ដើម្បីឱ្យប្រជាពលរដ្ឋប្រើសិទ្ធិរបស់ខ្លួនស្របតាមច្បាប់ **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** សូមអំពាវនាវចំពោះគ្រប់ម្ចាស់សហគ្រាស ក្រុមហ៊ុន រោងចក្រ សណ្ឋាគារ ភោជនីយដ្ឋាន និងគ្រឹះស្ថានទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមជួយបង្កលក្ខណៈងាយស្រួល និងអនុញ្ញាតឱ្យនិយោជិត កម្មករ-កម្មការិនី បានធ្វើដំណើរទៅបោះឆ្នោត នៅ**ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣** នៅតាមឃុំ សង្កាត់ ដែលពួកគាត់បានចុះឈ្មោះបោះឆ្នោត។

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** សង្ឃឹមយ៉ាងមុតមាំថា គ្រប់ម្ចាស់សហគ្រាស ក្រុមហ៊ុន រោងចក្រ សណ្ឋាគារ ភោជនីយដ្ឋាន និងគ្រឹះស្ថានទាំងអស់ នឹងបង្កលក្ខណៈងាយស្រួលដល់និយោជិត កម្មករ-កម្មការិនីបានទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅ**ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣** ជាកំណត់៕

ថ្ងៃសុក្រ ៥រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែកក្កដា ឆ្នាំ២០២៣
ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

ប្រាជ្ញ ចន្ទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ✓ គ.ជ.ប

## លទ្ធផលផ្លូវការនៃការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

| ល.រ. | គណបក្ស | ចំនួនមណ្ឌលឈរឈ្មោះ | | ចំនួន ការិ. បោះឆ្នោតសរុបនៃមណ្ឌលឈរឈ្មោះ | | ចំនួនភ្នាក់ងារគណបក្សនយោបាយ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ភ្នាក់ងារពេញសិទ្ធិ | | ភ្នាក់ងារបម្រុង | | សរុបរួម | |
| | | សរុប | ដាក់ភ្នាក់ងារ | សរុប | ដាក់ភ្នាក់ងារ | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 1 | ប្រជាជនកម្ពុជា | 25 | 25 | 23,789 | 23,789 | 23,789 | 5,438 | 23,789 | 7,632 | 47,578 | 13,070 |
| 2 | យុវជនកម្ពុជា | 25 | 6 | 23,789 | 153 | 153 | 69 | 70 | 44 | 223 | 113 |
| 3 | ខ្មែររួបរួមជាតិ | 25 | 20 | 23,789 | 3,399 | 3,399 | 1,285 | 58 | 32 | 3,457 | 1,317 |
| 4 | ធម្មាធិបតេយ្យ | 25 | | 23,789 | | | | | | | |
| 5 | សញ្ជាតិកម្ពុជា | 25 | | 23,789 | | | | | | | |
| 6 | ខ្មែរតែមួយ | 25 | | 23,789 | | | | | | | |
| 7 | ហ្វ៊ុនស៊ិនប៉ិច | 25 | 18 | 23,789 | 4,862 | 4,862 | 1,747 | 698 | 313 | 5,560 | 2,060 |
| 8 | ខ្មែរឈប់ក្រ | 25 | 2 | 23,789 | 17 | 17 | 10 | | | 17 | 10 |
| 9 | ជនជាតិដើមប្រជាធិបតេយ្យកម្ពុជា | 22 | | 18,472 | | | | | | | |
| 10 | ស្ត្រីដើម្បីស្ត្រី | 18 | | 13,917 | | | | | | | |
| 11 | កម្លាំងប្រជាធិបតេយ្យ | 12 | | 12,166 | | | | | | | |
| 12 | ប្រជាធិបតេយ្យមូលដ្ឋាន | 12 | | 16,000 | | | | | | | |
| 13 | បំណងពលរដ្ឋ | 9 | | 9,449 | | | | | | | |
| 14 | កសិករ | 8 | | 9,609 | | | | | | | |
| 15 | ឯកភាពជាតិខ្មែរ | 7 | 3 | 9,223 | 139 | 139 | 45 | | | 139 | 45 |
| 16 | ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | 7 | 2 | 10,928 | 6 | 6 | 3 | 2 | | 8 | 3 |
| 17 | ខ្មែរអភិរក្ស | 7 | | 9,427 | | | | | | | |
| 18 | សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ | 6 | 1 | 10,189 | 15 | 15 | 4 | 15 | 2 | 30 | 6 |
| | | | | | **សរុបរួម** | **32,380** | **8,601** | **24,632** | **8,023** | **57,012** | **16,624** |

ថ្ងៃចន្ទ ១រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែកក្កដា ឆ្នាំ២០២៣

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
ទូរស័ព្ទ : 023 235 271
អ៊ីម៉ែល : info@nec.gov.kh

# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

គ.ជ.ប

## ការគូសសញ្ញាគាំទ្រគណបក្សលើសន្លឹកឆ្នោត

### ១ លោកអ្នកត្រូវគូសសញ្ញាណាមួយ ដូចខាងក្រោម៖

✓ ឬ X ឬ + ឬ - ឬ / ឬ \ ឬ V ឬ U ឬ ∩ ឬ 0

( ឬ ) ឬ ~ ជាដើម ឬគូសសញ្ញាណាដែលគេមិនអាចស្គាល់អត្តសញ្ញាណរបស់អ្នកបោះឆ្នោត

### ២ សន្លឹកឆ្នោតដែលមិនអាចយកជាការបាន មានដូចជា៖

- សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ
- សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ
- សន្លឹកឆ្នោតមានបិទតែម ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗ
- សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយ
- សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អត្តសញ្ញាណរបស់អ្នកបោះឆ្នោតជាដើម

### ៣ គ.ជ.ប សូមលើកទឹកចិត្តឱ្យគូសសញ្ញាដូចខាងក្រោម៖

✓

រៀបរៀង និងបោះពុម្ពផ្សាយដោយ
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ទីស្តីការ គ.ជ.ប វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទ (Tel) : (+855) 23 235 271
អ៊ីម៉ែល(Email): info@nec.gov.kh
Website: www.nec.gov.kh, voterlist.nec.gov.kh
Facebook/Youtube: National Election Committee
APP: NEC KH, CamNEC News